# តោះឆែកមើល ប្រាក់បៀវត្សអប្បបរមា!



## ទាំងនិយោជក
## ទាំងនិយោជិត
## ទៅវិញទៅមក។

វាជាវិធានសម្រាប់អ្នកធ្វើការគ្រប់គ្នា
ដូចជាបុគ្គលិកក្រុមហ៊ុនពេញសិទ្ធិ
អ្នកធ្វើការងារក្រៅម៉ោង
អ្នកធ្វើការតាមកិច្ចសន្យា
និងសិស្សនិស្សិតជាដើម
និងសម្រាប់អ្នកជួលបុគ្គលិក
ឲ្យធ្វើការងារ។

---

## ខេត្តកាហ្គាវ៉ា ប្រាក់បៀវត្សអប្បបរមា

---

ចាប់ពីថ្ងៃទី1
ខែតុលា
ឆ្នាំ2023 នេះតទៅ

ចំនួនទឹកប្រាក់
ក្នុងមួយម៉ោង

# 918 យ៉េន

ធៀបនឹងឆ្នាំមុន
40 យ៉េន
UP

カンボジア語版

ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។

ឆែកតាម
WEB!!

វេបសាយពិសេស
ដែលទាក់ទងនឹង
ប្រាក់បៀវត្ស
អប្បបរមា
(មានតែភាសាជប៉ុន):

最低賃金制度 検索

ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បបរមា សូម
ទាក់ទងមកនាយកដ្ឋានការងារ
ខេត្តកាហ្គាវ៉ា ឬការិយាល័យត្រួតត្រា
ស្តង់ដារការងារនៅជិតលោកអ្នកបំផុត។

香川労働局 検索

វេបសាយពិសេសអំពី
ការដំឡើងប្រាក់ឈ្នួល
(មានតែភាសាជប៉ុន):
មានផ្សព្វផ្សាយអំពីគោលនយោបាយ
គាំទ្រសម្រាប់ការដំឡើងប្រាក់ឈ្នួល។

賃金引上げ特設ページ 検索

ចំពោះលោក លោកស្រីដែលជាម្ចាស់
ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

業務改善
助成金

ជួយឧបត្ថម្ភយ៉ាង
ច្រើនបំផុតត្រឹម
600 ម៉ឺនយ៉េន

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព

# "ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា"

## គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្ស (ចំនួនទឹកប្រាក់បៀវត្សអប្បបរមា) សម្រាប់បុគ្គលិកគ្រប់គ្នា!

ត្រូវអនុវត្តចំពោះបុគ្គលិកទាំងអស់ ទោះបីជាមានអាយុ ឬរបៀបធ្វើការខុសគ្នា ដូចជាការងារមិនពេញម៉ោង ឬការងារក្រៅម៉ោងរបស់សិស្សនិស្សិតជាដើមក៏ដោយ។



## របៀបឆែកមើលដូចម្តេច?

សូមគណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងរបស់ប្រាក់បៀវត្សដែលចង់ឆែក (*1) រួចយកវាមកប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)!

**វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា** សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តដែលត្រូវនឹងអ្នក។(*2)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **1** ក្នុងករណីប្រាក់ខែតាមម៉ោង | ប្រាក់ខែតាមម៉ោង<br>យ៉េន | ≥ | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)<br>យ៉េន | | | | | |
| **2** ក្នុងករណីប្រាក់ខែតាមថ្ងៃ | ប្រាក់ខែតាមថ្ងៃ<br>យ៉េន | ÷ | ចំនួនមធ្យមនៃម៉ោងធ្វើការក្នុងមួយថ្ងៃដែលកំណត់<br>ម៉ោង | = | ចំនួនទឹកប្រាក់ក្នុងមួយម៉ោង<br>យ៉េន | ≥ | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)<br>យ៉េន | |
| **3** ក្នុងករណីប្រាក់ខែតាមខែ | ប្រាក់ខែតាមខែ<br>យ៉េន | ÷ | ចំនួនមធ្យមនៃម៉ោងធ្វើការក្នុង១ខែដែលកំណត់<br>ម៉ោង | = | ចំនួនទឹកប្រាក់ក្នុងមួយម៉ោង<br>យ៉េន | ≥ | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)<br>យ៉េន | |

**4** ក្នុងករណីដែលរួមបញ្ចូលគ្នាចំណុច **1 2** និង **3** ខាងលើនេះ

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

❶ ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា **2**
❷ ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា **3**
❸ ចំនួនទឹកប្រាក់សរុបដែលបូក ❶ និង ❷ ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖ ① ប្រាក់បៀវត្សដែលទូទាត់បណ្តោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើសពី១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនមែនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក (ប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ

(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធផលស្នាដៃ សូមទាក់ទងមកការិយាល័យត្រួតត្រាស្តង់ដារការងារឬនាយកដ្ឋានការងារនៅជិតលោកអ្នកបំផុត

## ទាំងនិយោជក និងនិយោជិត ត្រូវពិនិត្យមើលប្រាក់បៀវត្សអប្បបរមាកុំខាន។

តោះ ឆែកប្រាក់បៀវត្សអប្បបរមាក្នុងតំបន់ខ្លួនឯងនៅលើទូរសព្ទដៃ និងស្មាតហ្វូន! (មានតែភាសាជប៉ុន)

### ចំពោះលោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

តោះនាំគ្នាប្រើប្រាស់ឲ្យសកម្មនូវប្រាក់ឧបត្ថម្ភដែលគាំទ្រការដំឡើងប្រាក់បៀវត្ស។

**業務改善助成金**

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុតត្រឹម 600 ម៉ឺនយ៉េន

មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទអំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច **0120-366-440**

### អ្វីទៅជា "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច"

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" គឺជាប្រាក់ឧបត្ថម្ភដែលផ្តល់ជំនួយដល់សហគ្រាសតូចនិងមធ្យម និងប្រតិបត្តិករអាជីវកម្មខ្នាតតូច ដែលមានគោលដៅបង្កើនផលិតភាពនិងដំឡើង "ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម(ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម)" ។ ក្នុងករណីដែលបានធ្វើការវិនិយោគលើសម្ភារៈជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះ អាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ: (មានតែភាសាជប៉ុន) 業務改善助成金 検索

**លក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ**

1. ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
2. ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
3. ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍និងសម្ភារៈជាដើមដើម្បីបង្កើនផលិតភាព
4. គ្មានមូលហេតុនៃការមិនផ្តល់ការឧបត្ថម្ភដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

▶ ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម

ឆែកមើលខ្លឹមសារសង្ខេបតាមវីដេអូ! (មានតែភាសាជប៉ុន)

**ជំហានរហូតដល់ការផ្តល់ប្រាក់ឧបត្ថម្ភ**

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភនិងផែនការអនុវត្តគម្រោងជាដើមទៅនាយកដ្ឋានការងារនៃរាជធានីខេត្តដែលកន្លែងធ្វើអាជីវកម្មស្ថិតនៅ

▶ ត្រួតពិនិត្យ

2. ក្រោយសម្រេចផ្តល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការដែលបានដាក់ពាក្យមក

▶

3. ដាក់របាយការណ៍លទ្ធផលនៃការអនុវត្ត និងពាក្យស្នើសុំផ្តល់ប្រាក់ឧបត្ថម្ភទៅនាយកដ្ឋានការងារ

▶ ត្រួតពិនិត្យ

4. ផ្តល់ឲ្យ

ឆែកមើលបែបបទតាមវីដេអូ! (មានតែភាសាជប៉ុន)

### ផ្តល់ការពិភាក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ

អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស សូមពិភាក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援センター 検索

### មូលនិធិគាំទ្រកំណែទម្រង់របៀបការងារ

សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងផ្តល់ហិរញ្ញប្បទានសម្រាប់បរិក្ខារនិងប្រតិបត្តិការទៅកាន់និយោជកដែលខិតខំប្រឹងប្រែងដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុងកន្លែងធ្វើអាជីវកម្ម។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援資金 検索

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。

(R5.9)